# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ១០៦១ មស.រប

ថ្ងៃ ពុធ ១០កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០២១

**សូមគោរពជូន**
**សម្តេច ឯកឧត្តម លោកជំទាវ**
**ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងប្រធានស្ថាប័ន អង្គភាពនានា នៅថ្នាក់ជាតិ**
**ឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ៖** សំណើសុំមេត្តាផ្តល់ជាបន្ទាន់នូវចំនួនមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាដែលនៅមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ដោយគិតមកដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១។

**យោង៖** មតិណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ ពាក់ព័ន្ធការចាក់វ៉ាក់សាំងកូវីដ-១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា ដើម្បីអនុវត្តតាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងមុខងារសាធារណៈ សូមគោរពស្នើសុំផ្តល់ជាបន្ទាន់នូវចំនួនមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួង ស្ថាប័ន អង្គភាព រដ្ឋបាលរាជធានី ខេត្ត (ដោយមិនរាប់បញ្ចូលកងកម្លាំងប្រដាប់អាវុធ) ដែលនៅមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ដោយគិតមកដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១។

អាស្រ័យហេតុនេះ ខ្ញុំសូមស្នើ **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាស្រង់ចំនួនមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាខាងលើតាមគំរូបញ្ជីដែលភ្ជាប់មកជាមួយ រួចផ្ញើជាបន្ទាន់មកក្រសួងមុខងារសាធារណៈ ឱ្យបានមុនថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ ដើម្បីធ្វើការបូកសរុបគោរពផ្ញើជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ឲ្យបានទាន់ពេលវេលា។

សូមមេត្តាទំនាក់ទំនងតាមរយៈ Telegram/ទូរស័ព្ទលេខ: 015 21 44 44 ឬ 017 89 82 58 ឬ 070 67 64 03។

សូម **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**រដ្ឋមន្ត្រី**

ព្រុំ សុខា

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
  "ដើម្បីគោរពជូនជ្រាប"
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិ
- រដ្ឋបាលរាជធានី ខេត្ត
- ប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ឯកសារ កាលប្បវត្តិ

**ឈ្មោះ ក្រសួង ស្ថាប័ន អង្គភាព**...................................

**ចំនួនមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាដែលនៅមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩**

| ល.រ. | មន្ត្រី | ចំនួន | ចំនួនអ្នកមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ | មូលហេតុ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | មន្ត្រីក្របខណ្ឌ | | | | |
| ២ | មន្ត្រីជាប់កិច្ចសន្យា | | | | |
| សរុប | | | | | (គិតជាភាគរយ%) |